00154420

**Declassified to Public**
**06 September 2012**


គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា

**CAMBODIAN HUMAN RIGHTS ACTION COMMITTEE**

ADHOC - CARAM Cambodia - CCPCR - CDP - CHHRA - CKIMHRDA - CSD- CWCC - GENEROUS – HROTP
IDA- KID – KIND- KKKHRO - KKKHRDA - KSA - KYA - LAC - OUTREACH - PDP- PJJ - TASK FORCE - VIGILANCE
#9Eo, St. 330, Sangkat Boeung Kengkang III, Khan Chamkarnorn, Phnom Penh, Tel/Fax: 023 351 415, E-mail: chrac@forum.org.kh


# សារណារបស់មិត្តតុលាការ
# ទាក់ទិននឹងការប្តឹងឧទ្ធរណ៍របស់លោក កាំង ហ្គេចអ៊ាវ ហៅ ឌុច
# ជំទាស់ទៅនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត

ដាក់បញ្ជូនដោយៈ គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា

ភ្នំពេញ ថ្ងៃទី២ ខែតុលា ឆ្នាំ២០០៧

**សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងតំណាងគណៈកម្មាធិការប្រព្រឹត្តិកម្មៈ**

- លោក **ធន សារាយ** *ប្រធានសំរបសំរួលគណៈកម្មធិការប្រព្រឹត្តិកម្ម និងជាប្រធានសមាគមអាដហុក (លេខៈ ០១៦ ៨៨០ ៥០៩)*
- លោក **សុក សំអឿន** *នាយកប្រតិបត្តិក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (លេខៈ ០១២ ៩០១ ១៩៩)*
- កញ្ញា **សេង ធារី** *នាយិកាមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (០១២ ២២២ ៥២២)*
- លោកស្រី **ណៃ ឌីណា** *នាយិកាប្រតិបត្តិវិទ្យាស្ថានដើម្បីលទ្ធិប្រជាធិបតេយ្យ (លេខៈ ០១១ ៩២៤ ២៨៦)*
- លោកស្រី **ពឹង យុកហៀប** *នាយិកាប្រតិបត្តិជំនួយផ្នែកច្បាប់នៅកម្ពុជា (លេខៈ ០១២ ៨២៣ ៧៤៥)*

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
THE PRE TRIAL CHAMBER OF THE ECCC
លេខ No.: 001
ថ្ងៃទី 03-10-2007
Date:
ម៉ោងចូល 11H 50 AM
Time

00154421

## ផលប្រយោជន៍របស់មិត្តតុលាការ

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៤។ បច្ចុប្បន្ន គណៈកម្មាធិការប្រព្រឹត្តិកម្ម គឺជាសម្ព័ន្ធ នៃ សមាគម អង្គការមិនមែនរដ្ឋាភិបាល ដែលមានសមាជិកចំនួន ២៣ បង្កើតឡើង ដើម្បីជួយដោះស្រាយស្ថានភាពសិទ្ធិមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គណៈកម្មាធិការប្រព្រឹត្តិកម្ម មានគំរោងទាក់ទិននឹងសាលាក្តីខ្មែរក្រហម ដែលបាននឹងកំពុងធ្វើការលើវិស័យផ្សព្វផ្សាយព័ត៌មាន តស៊ូមតិ និងសង្កេតឃ្លាំមើលដំណើរការនានាទាក់ទិននឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC)។ គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមបញ្ជូននូវសារណារមួយទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងឋានៈជា មិត្តតុលាការ ដោយយោងទៅលើទំនាក់ទំនងរបស់ខ្លួនដ៏យូរជាមួយអង្គជំនុំជម្រះនេះកន្លងមក ការប្រាស្រ័យទាក់ទងជាមួយប្រជាជនកម្ពុជា និងប្រវត្តិនៃបញ្ហាសំខាន់ៗទាក់ទិននឹងអង្គជំនុំជម្រះវិសាមញ្ញនេះ។

## សេចក្តីថ្លែងអំពីអង្គហេតុ

លោក **កាំង ហ្គេចអ៊ាវ** ហៅ **ឌុច** បានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត នៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានចេញកាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧។ **ឌុច** បានប្តឹងឧទ្ធរណ៍ដោយយោងទៅលើគំនិតដែលថា ការឃុំខ្លួនគាត់ដោយតុលាការយោធាក្រុងភ្នំពេញ ចាប់តាំងពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៧ និងការចាប់បញ្ជូនដោយផ្ទេរការឃុំខ្លួននេះទៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ គឺជាការបញ្ជាក់នូវការរំលោភទាំងច្បាប់កម្ពុជា និងស្តង់ដារអន្តរជាតិ ដែលទាក់ទិននឹងសិទ្ធិទទួលនូវការជំនុំជម្រះក្នុងពេលវេលាសមស្របមួយ។

## ខ្លឹមសារសង្ខេប

គណៈកម្មាធិការប្រព្រឹត្តិកម្ម យល់ឃើញថា ការបន្តឃុំខ្លួន **ឌុច** ដោយអង្គជំនុំជម្រះវិសាមញ្ញ គឺជាការចាំបាច់ ហើយថាហេតុផលដែលបានលើកឡើងដោយសហចៅក្រមស៊ើបអង្កេត គឺជាការត្រឹមត្រូវក្នុងការអនុវត្តច្បាប់ ទាក់ទិននឹងគោលការណ៍ *male captus bene detentus* និងវិធាន ៦៣ នៃ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ។

សារណានេះពិនិត្យមើលអំពីសំណួរដូចគ្នាដែលបានពិភាក្សានៅក្នុងដីកាឃុំខ្លួនបណ្តោះអាសន្ន ថាតើ ការឃុំខ្លួន **ឌុច** កាលពីនៅតុលាការយោធាក្រុងភ្នំពេញ ប៉ះពាល់ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញដែរឬទេ។ គោលការណ៍ *male captus bene detentus* ការរំលោភបំពាននីតិវិធី (abuse of process) និងសមាមាត្រកម្ម (proportionality) នឹងត្រូវយកមកពិចារណា ព្រមទាំង ការអនុវត្តវិធាន៦៣នៃវិធានផ្ទៃក្នុងក៏នឹងត្រូវពិនិត្យផងដែរ។ អំណះអំណាងបន្ថែមផ្សេងទៀត (additional arguments) នឹងត្រូវផ្តល់ទៅលើអំណះអំណាង ដែលបានលើកឡើងដោយ **ឌុច** នៅក្នុងការប្តឹងឧទ្ធរណ៍របស់គាត់ ព្រមទាំងទៅលើលទ្ធភាពនៃការសំរេចដាក់ពន្ធនាគារ ដែល **ឌុច** ប្រសិនបើ **ឌុច** ត្រូវកាត់ឱ្យជាប់ទោសដោយអង្គជំនុំជម្រះវិសាមញ្ញ។

ការឃុំឃាំងអស់រយៈពេលដ៏យូរនៅពន្ធនាគារ នៃតុលាការយោធាក្រុងភ្នំពេញ អាចត្រូវមើលឃើញជាការខុសច្បាប់ និងគួរតែត្រូវថ្កោលទោសដោយសារវាផ្ទុយទៅនឹងស្តង់ដារអន្តរជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ គណៈកម្មាធិការប្រព្រឹត្តិកម្ម យល់ឃើញថា ការឃុំខ្លួន **ឌុច** នៅតុលាការយោធាក្រុងភ្នំពេញមិនប៉ះពាល់ដល់ស្ថានភាពនៃការឃុំខ្លួនគាត់ដោយអង្គជំនុំជម្រះវិសាមញ្ញ ហើយក៏មិនផ្តល់ហេតុផលគ្រប់គ្រាន់សំរាប់ការស្នើសុំដោះលែងគាត់ឱ្យនៅក្រៅឃុំនោះដែរ។

ដូចបានបង្ហាញនៅក្នុងសារណានេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម គិតឃើញថា ការបន្តឃុំខ្លួន **ឌុច** ដោយអង្គជំនុំជម្រះវិសាមញ្ញ គឺមិនរំលោភបំពានទៅលើស្តង់ដារអន្តរជាតិនោះទេ។ ជាងនេះទៅទៀត អង្គជំនុំជម្រះវិសាមញ្ញបានធ្វើស្របទៅនឹងគោលការណ៍អន្តរជាតិ និងអាចពឹងផ្អែកទៅលើយុត្តិសាស្ត្រដែលមានពីមុនៗ និងគោលការណ៍សមាមាត្រកម្ម ដើម្បីបញ្ជាក់អំពីដីកាឃុំខ្លួនបណ្តោះអាសន្ននេះថាពិតជាត្រឹមត្រូវ។

គណៈកម្មាធិការប្រព្រឹត្តិកម្ម ជឿជាក់យ៉ាងមុតមាំថា ការបន្តឃុំខ្លួន **ឌុច** ជាការចាំបាច់ ដើម្បីលើកស្ទួយសុច្ចរិតភាពរបស់តុលាការវិសាមញ្ញនេះ នៅក្នុងក្រសែភ្នែករបស់ប្រជាពលរដ្ឋកម្ពុជាទាំងមូល។

### **អំណះអំណាង** (**Arguments**)

វាប្រាកដណាស់ថា សិទ្ធិមនុស្សរបស់មនុស្សទាំងអស់ ត្រូវតែគោរពគ្រប់ពេលវេលា និងទីកន្លែងទាំងអស់។ ការពិតដែលថា បុគ្គលម្នាក់ត្រូវបានគេចោទប្រកាន់ថាបានប្រព្រឹត្តអំពើណាមួយ ដែលធ្វើឱ្យខុសទៅនឹងការដឹងលឺរបស់មនុស្សទូទៅមិនប៉ះពាល់ដល់ការពិតដែលថា ការសន្មត់ជាមុនថា គ្មានទោស ត្រូវតែមានលើសលុប ហើយសិទ្ធិមនុស្សរបស់ជនជាប់ចោទត្រូវតែរក្សាឱ្យបាននោះទេ។ **ឌុច** បានលើកឡើងថា ការបន្តឃុំខ្លួនគាត់ និងការខ្វះការជំនុំជម្រះគាត់នៅក្នុងពេលវេលាសមស្របមួយគឺជាការរំលោភសិទ្ធិមនុស្ស។ ដោយសារហេតុនេះហើយ ទើបគណៈកម្មាធិការប្រព្រឹត្តិកម្មពិនិត្យមើលករណីនេះយ៉ាងប្រុងប្រយ័ត្នមុនពេលសន្និដ្ឋានថា ដីកាឃុំខ្លួនបណ្តោះអាសន្ននេះ ត្រូវរក្សាតែនៅដដែល។

### **គោលការណ៍** ***male captus bene detentus*****, ការរំលោភបំពាននីតិវិធី** (**abuse of process**) **និង សមាមាត្រកម្ម** (**proportionality**)

ដូចបានបញ្ជាក់នៅក្នុងដីកាឃុំខ្លួនបណ្តោះអាសន្ន គោលការណ៍ *male captus bene detentus* គឺមានភាពទាក់ទងគ្នាជាសំខាន់ទៅលើករណីនេះណាស់។ គោលការណ៍ ដែលបកស្រាយតាមន័យសាមញ្ញថា “ចាប់ខ្លួនដោយលំបាក តែឃុំខ្លួនបានល្អ” បញ្ជាក់ថាតុលាការអាចនៅក្រោមយុត្តាធិការរបស់តុលាការ។ គោលការណ៍នេះត្រូវកំរិតនៅក្នុងការអនុវត្តដោយទ្រឹស្តី “ការរំលោភបំពាននីតិវិធី” ដែលមានន័យថា តុលាការអាចមិនបន្តដំណើរការប្រឆាំងនឹងជនជាប់ចោទ បើសិទ្ធិរបស់ជនជាប់ចោទត្រូវបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ក្នុងគោលបំណងដើម្បីរក្សាសុច្ចរិតភាពរបស់តុលាការ។ ទ្រឹស្តីនៃការរំលោភបំពាននីតិវិធីនេះ ត្រូវបានគេទទួលស្គាល់ និងអនុវត្តន៏យ៉ាងទូលំទូលាយ ប៉ុន្តែត្រូវកំរិតនៅក្នុងការអនុវត្តដោយតំរូវការ នៃសមាមាត្រកម្ម។ នៅទីណាដែលមានការរំលោភបំពាននីតិវិធីកើតឡើង តុលាការត្រូវពិចារណាទំនាក់ទំនងជាសមាមាត្ររវាងឧក្រិដ្ឋកម្មត្រូវបានចោទប្រកាន់ដែលបានប្រព្រឹត្តឡើងដោយជនជាប់ចោទ និងផលប៉ះពាល់នៃសំណងប៉ះប៉ូវដែលត្រូវទាមទារដោយជនជាប់ចោទ។

វាប្រាកដតាមរយៈករណីច្បាប់នៃបណ្តាប្រទេសជាច្រើន និងពីយុត្តិសាស្ត្រពីមុនៗដែលបង្កើតដោយសាលាក្តីអន្តរជាតិថា ដើម្បីឱ្យមានការរំលោភបំពាននីតិវិធីធ្វើឡើងជាបញ្ហាប្រឈមទៅនឹងគោលការណ៍ *male captus bene detentus* នោះការរំលោភបំពានសិទ្ធិរបស់ជនជាប់ចោទត្រូវតែចាត់ទុកថា *ធ្ងន់ធ្ងរ និងអាក្រក់ខ្លាំងបំផុត*[១]។ ករណីរបស់ *Nikolic* នៅ

[១] សេចក្តីសង្ខេបអំពីករណីច្បាប់ជាតិ និងយុត្តិសាស្ត្រអន្តរជាតិពីមុនៗ អាចរកបាននៅក្នុងដីកាឃុំខ្លួនបណ្តោះអាសន្ន។ សេចក្តីលំអិតបន្ថែមអាចរកបាននៅក្នុងករណី *Nikolic* នៃតុលាការដំបូង II របស់សាលាក្តីអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី (ICTY), ៩ តុលា ២០០២ IT-៩៤-២-PT

00154423

ក្នុងសាលាក្ដីអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី (ICTY) ត្រូវបានដកស្រង់ដោយសហចៅក្រមស៊ើបអង្កេត និងចាត់ទុកជាសេចក្ដីថ្លែងការណ៍ដ៏ខ្លាំងបំផុតមួយរបស់ច្បាប់ទៅលើបញ្ហានេះ គឺថា "ដើម្បីឱ្យតុលាការប្រើទ្រឹស្ដីនេះកាន់តែរហ័ស វាត្រូវការឱ្យច្បាស់ថា សិទ្ធិរបស់ជនជាប់ចោទត្រូវបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរបំផុត។"[២] នៅក្នុងឧទាហរណ៍នេះ គេត្រូវពិចារណាថាតើ ការបន្តឃុំខ្លួន **ឌុច** គឺជាការរំលោភសិទ្ធិរបស់គាត់យ៉ាងធ្ងន់ធ្ងរឬយ៉ាងណា ដើម្បីឱ្យការរំលោភបំពាននេះអាចត្រូវគេពិចារណាថ្លឹងថ្លែងធ្ងន់ជាងបទឧក្រិដ្ឋដែលគាត់ត្រូវគេចោទប្រកាន់ និងការតំរូវឱ្យដោះលែងគាត់។

គណៈកម្មាធិការប្រព្រឹត្តិកម្មយល់ឃើញថា បទឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ប្រព្រឹត្តឡើងដោយ **ឌុច** បញ្ជាក់ថាភាពអយុត្តិធម៌ដ៏ធ្ងន់ធ្ងរសំរាប់ប្រជាពលរដ្ឋកម្ពុជា និងមិនអាចបំភ្លេចចោលឡើយ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានទំហំធំដោយសារវាមានធម្មជាតិធ្ងន់ធ្ងររបស់វា ដែលបទល្មើសនេះមិនគ្រាន់តែប្រឆាំងទៅនឹងជនដែលរងគ្រោះប៉ុណ្ណោះទេ ថែមទាំងប្រឆាំងទៅនឹងមនុស្សជាតិទាំងមូលផងដែរ។ ការស្នើសុំឱ្យមានការជួសជុលសំណងនៅក្នុងករណីនេះ- ការដោះលែង **ឌុច** ឱ្យនៅក្រៅឃុំ-នឹងក្លាយទៅរឿងខកចិត្តជាខ្លាំងចំពោះបទឧក្រិដ្ឋដែលចោទប្រកាន់ថាបានប្រព្រឹត្តឡើងហើយមិនត្រូវតាមការតំរូវការ នៃសមាមាត្រកម្មជាមួយនឹងលក្ខខណ្ឌឱ្យនៅក្រៅឃុំភ្ជាប់ជាមួយ។ វាពិតណាស់ថា **ឌុច** ត្រូវបានគេឃុំឃាំងចំពោះអ្វី ដែលអាចត្រូវបានគេចាត់ទុកថា មានពេលវេលាមិនសមស្រប ប៉ុន្តែ គណៈកម្មាធិការប្រព្រឹត្តិកម្មជឿជាក់ថា អង្គជំនុំជម្រះវិសាមញ្ញនឹងកែតំរូវរឿងហេតុនេះ ដោយការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស ចាប់ពីពេលដែលអង្គជំនុំជម្រះនេះត្រូវបានគេផ្ដល់យុត្តាធិការឱ្យធ្វើកិច្ចការនេះ។ គេមិនឃើញមានការបញ្ជាក់នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ **ឌុច** ដែលថា គាត់ត្រូវបានរងនូវការប្រព្រឹត្តធ្ងន់ធ្ងរនៅក្នុងរយៈពេលនៃការឃុំឃាំង ដើម្បីបង្កឱ្យកើតមានឡើងនូវស្ថានភាពរំលោភបំពានសិទ្ធិរបស់គាត់ធ្ងន់ធ្ងរនៅពេលប្រៀបធៀបទៅនឹងបទឧក្រិដ្ឋដែលគាត់ត្រូវបានចោទប្រកាន់នោះទេ។

ដូចនេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម យល់ស្របជាមួយនឹងសេចក្ដីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតដែលថាទ្រឹស្ដី នៃ "ការរំលោភបំពាននីតិវិធី" មិនអនុវត្តន៍បាននៅក្នុងករណីបច្ចុប្បន្ននេះ ពីព្រោះការរំលោភបំពានដែល **ឌុច** រងគ្រោះក្នុងកំឡុងពេលឃុំឃាំងដ៏យូរមិនអាចចាត់ទុកថាជា មានលក្ខណៈធ្ងន់ធ្ងរ ដើម្បីឱ្យអាចថ្លឹងថ្លែងធ្ងន់ជាងបទឧក្រិដ្ឋដែលគាត់ត្រូវបានគេចោទប្រកាន់នោះឡើយ។

## យុត្តាធិការ

គណៈកម្មាធិការប្រព្រឹត្តិកម្ម យល់ឃើញថា អង្គជំនុំជម្រះវិសាមញ្ញមិនអាចត្រូវគេមើលឃើញថាមានទំនាក់ទំនងជាមួយនឹងតុលាការយោធា ដែលបានឃុំខ្លួន **ឌុច** តាំងពីឆ្នាំ១៩៩៩នោះទេ។ អង្គជំនុំជម្រះវិសាមញ្ញមិនមានសមត្ថកិច្ចផ្លូវច្បាប់ទៅលើយុត្តាធិការរបស់តុលាការយោធា ហើយក៏មិនមានលទ្ធភាពជះឥទ្ធិពលទៅលើការឃុំឃាំងខ្លួនពេលមុនរបស់ **ឌុច** ដែរ។ នៅពេលដែលអង្គជំនុំជម្រះវិសាមញ្ញ ចាប់ប្រតិបត្តិការនៅខែមិថុនា ឆ្នាំ២០០៧ អង្គជំនុំជម្រះនេះ បានធ្វើសកម្មភាពយ៉ាងឆាប់រហ័ស និងគិតគូរយ៉ាងពេញលេញទៅលើនីតិវិធីច្បាប់ និងគោរពទៅតាមច្បាប់ចំពោះការឃុំខ្លួន និងចោទប្រកាន់ទៅលើ **ឌុច**។ ផ្ទុយទៅនឹងការលើកឡើងរបស់ជនត្រូវចោទ គេអាចនិយាយបានថា អង្គជំនុំជម្រះវិសាមញ្ញស្របទៅតាមស្តង់ដារអន្តរជាតិដោយបានចេញដីកាចាប់ខ្លួនយ៉ាងឆាប់រហ័សតាមដែលអាចធ្វើទៅបានដោយឃុំខ្លួន **ឌុច** នៅក្នុងមន្ទីរឃុំឃាំងដែលមានលក្ខណៈ

---

[២] ករណី *Nikolic* នៃតុលាការជំនុំជម្រះដំបូង II របស់សាលាក្ដីអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី (ICTY), ៩ តុលា ២០០២ IT-៩៤-២-PT។ សេចក្ដីសំរេចអំពី ញត្តិរបស់ផ្នែកការពារក្ដីប្រឆាំងទល់នឹងការប្រើប្រាស់យុត្តាធិការដោយសាលាក្ដី។

ល្អលើសពីមន្ទីរឃុំឃាំងនៅឯតុលាការយោធា ដោយមិនមានការពន្យាពេលជំនុំជម្រះ ហើយដោយផ្តល់ដល់ **ឌុច** នូវសិទ្ធិមានមេធាវីការពារយ៉ាងពេញលេញ។ តាមរយៈនេះ អង្គជំនុំជម្រះវិសាមញ្ញបានបង្ហាញនូវការគោរពនូវស្តង់ដារអន្តរជាតិ និងធ្វើសកម្មភាព ដើម្បីលើកស្ទួយស្តង់ដារអន្តរជាតិទាំងនេះយ៉ាងឆាប់រហ័សតាមដែលអាចធ្វើទៅបាន ដោយសារនេះជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះដែលត្រូវធ្វើកិច្ចការដូចនេះ។

### ការពិចារណានៅលើវិធាន ៦៣ នៃ វិធានផ្ទៃក្នុង

ដូចដែលបានបញ្ជាក់ដោយសហចៅក្រមស៊ើបអង្កេត លក្ខខណ្ឌដែលបានចែងនៅក្នុងវិធាន ៦៣ នៃ វិធានផ្ទៃក្នុងត្រឹមត្រូវទៅតាមដីកាឃុំខ្លួន **ឌុច**។ ជាដំបូង វាចាំបាច់ដែលថា តុលាការមានហេតុផលគ្រប់គ្រាន់ ដែលជឿជាក់បុគ្គលនេះ ថាបានប្រព្រឹត្តបទល្មើសដែលគេបានចោទប្រកាន់។ នៅក្នុងករណីនេះ វាក៏បានលេចឡើងថា សហព្រះរាជអាជ្ញាបានប្រមូលភស្តុតាងគ្រប់គ្រាន់សំរាប់គាំទ្រការចោទប្រកាន់។ ជាការកត់សំគាល់ផងដែរថា **ឌុច** បានសារភាពថា ខ្លួន ធ្លាប់អ្នកដឹកនាំមន្ទីរឃុំឃាំង (S-២១) ហើយថា គាត់បានត្រៀមខ្លួនជាស្រេចសំរាប់បំភ្លឺបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយពួកខ្មែរក្រហម។

ក្នុងចំណោមមូលហេតុផ្សេងៗជាច្រើនសំរាប់ឃុំខ្លួន **ឌុច** សហចៅក្រមស៊ើបអង្កេតបានបង្ហាញពីសេចក្តីត្រូវការធានានូវវត្តមានរបស់ **ឌុច** នៅក្នុងពេលសវនាការ សន្តិសុខរបស់គាត់ និងរក្សាសន្តិសុខសាធារណៈ។ គណៈកម្មាធិការប្រព្រឹត្តិកម្មយល់ស្របជាខ្លាំងទៅលើការវាយតំលៃបែបនេះ។ ជាដំបូង ប្រសិនបើ **ឌុច** ត្រូវបានគេដោះលែងឱ្យនៅក្រៅឃុំ នោះតុលាការអាចមិនអាចធានាឱ្យមានវត្តមាននៅសវនាការ។ ការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចត្រូវជាប់ទោសរហូតដល់មួយជីវិត ជាទោសដែលអាចជំរុញឱ្យ**ឌុច**អាចរត់គេចចេញពីប្រទេសកម្ពុជា។ ភាពចាំបាច់ដើម្បីធានាវត្តមានរបស់ **ឌុច** នៅក្នុងពេលសវនាការ គឺជាការព្រួយបារម្ភខ្លាំងបំផុត[៣]។ ដោយសារតែគ្មានបទប្បញ្ញត្តិអំពីការកាត់ទោសដោយកំបាំងមុខនៅអង្គជំនុំជម្រះវិសាមញ្ញ ដូចនេះស្ថានភាពបែបនេះត្រូវតែចៀសវាងឱ្យបាន។ ទីពីរ គឺការកើនឡើងនូវការផ្សព្វផ្សាយជាសាធារណៈទាក់ទិននឹងការឃុំខ្លួន និងការជំនុំជម្រះមានសក្តានុពលដែលដាក់គាត់នៅក្នុងទីតាំងមួយ ដែលងាយរងគ្រោះ។ តុលាការមិនមានមធ្យោបាយអ្វីដែលអាចធានាអំពីសុវត្ថិភាពរបស់ **ឌុច** ទេ ប្រសិនបើគាត់ត្រូវបានគេដោះលែងឱ្យនៅក្រៅឃុំនោះ។ ទីបី វាទំនងថា **ឌុច** ត្រូវបានគេដោះលែង នោះសណ្តាប់ធ្នាប់សាធារណៈអាចត្រូវសំរបសំរួល។ គណៈកម្មាធិការប្រព្រឹត្តិកម្មយល់ច្បាស់ថា ប្រជាពលរដ្ឋកម្ពុជាមិនជឿជាក់ទៅលើតុលាការក្នុងស្រុក និងអង្គជំនុំជម្រះវិសាមញ្ញ ហើយថា ការដោះលែងឱ្យនៅក្រៅឃុំនៃជនត្រូវចោទដ៏សំខាន់ អាចធ្វើឱ្យអន្តរាយដល់ភាពជឿជាក់ទៅលើសមត្ថកិច្ចរបស់តុលាការក្នុងការផ្តល់យុត្តិធម៌។ ប្រជាពលរដ្ឋកម្ពុជាបានរងគ្រោះអស់រយៈពេលដ៏យូរ ហើយអាចប៉ះពាល់ដល់អារម្មណ៍របស់គេ ប្រសិន **ឌុច** ត្រូវបានគេជ្រើសរើសដោះលែងឱ្យនៅក្រៅឃុំនោះ ទោះបីជានៅក្នុងលក្ខខណ្ឌហ្មត់ចត់ណាមួយក៏ដោយ។ ការទាមទារឱ្យមានយុត្តិធម៌ត្រូវតែបន្តមាន ដើម្បីធានាថាការចងចាំរបស់ជនរងគ្រោះដោយរបបខ្មែរក្រហមត្រូវបានគោរព។

---

[៣] *វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ* " ការស្ទង់មតិអំពីរបបខ្មែរក្រហម និងសាលាក្តីខ្មែរក្រហម." ២០០៤. គេហទំព័រ: http://www.bigpond.com.kh/users/kid/KRT-Tribunal.htm ចំនួនកិច្ចសំភាសន៍ទាំងអស់មាន ៥៣៦ ធ្វើឡើងនៅទីក្រុងភ្នំពេញ និងខេត្ត/ក្រុងចំនួន ១០ ទៀត ពីថ្ងៃទី ១៦ ដល់ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤។ ៩៦ ភាគរយ នៃអ្នកឆ្លើយចង់បានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម។

## ការឆ្លើយតបទៅលើអំណះអំណាងផ្សេងទៀតដែលបានលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍

បញ្ហាពីរសំខាន់ ដែលបានលើកឡើងនៅក្នុងអំណះអំណាងរបស់ជនត្រូវចោទ ទាក់ទិននឹងការពិភាក្សាអំពីការចាប់ខ្លួនលើកនេះ។ ជាដំបូង **ឌុច** បានអធិប្បាយថា គាត់មិនមែនជា**មេដឹកនាំជាន់ខ្ពស់** ហើយថា “មានបុគ្គលជាងពីរពាន់នាក់” ដែលកាន់តំណែងជាប្រធានមជ្ឈមណ្ឌលសន្តិសុខ ដូចនេះគេមិនត្រូវចាត់ទុកគាត់អាចថាជា ជនជាប់ចោទនោះទេ។ យ៉ាងណាក៏ដោយ គណៈកម្មាធិការប្រព្រឹត្តិកម្មយល់ស្របជាមួយនឹងការវាយតំលៃថា**ឌុច** មិនមែនជាមេដឹកនាំជាន់ខ្ពស់ ប៉ុន្តែគណៈកម្មាធិការប្រព្រឹត្តិកម្មជឿជាក់ថា គាត់អាចសន្មត់តាមរយៈសកម្មភាពរបស់គាត់នៅក្នុងថ្នាក់ជា **“អ្នកទទួលខុសត្រូវជាន់ខ្ពស់”** ដែលជាប្រភេទជនជាប់ចោទមួយទៀតដែលបានកំនត់នៅក្រោមវិធានផ្ទៃក្នុង[4]។ មន្ទីរឃុំឃាំង S-២១ ជាគុកដែលធ្លាប់ស្ថិតក្រោមការដឹកនាំរបស់ **ឌុច** ធ្លាប់ជាទីដែលបានប្រព្រឹត្តការរំលោភបំពានដែលត្រូវបានចោទប្រកាន់ ប្រឆាំងទៅនឹងជនស៊ីវិល និងក៏ជាឧទាហរណ៍ដំបូងរបស់របបខ្មែរក្រហមដ៏អាក្រក់។ មន្ទីរឃុំឃាំងនេះ ក៏ត្រូវបានចាត់ទុកមណ្ឌលសន្តិសុខដែលកំរិតធ្ងន់ធ្ងរបំផុត និងជាភស្តុតាងដែលបញ្ជាក់ថាមានប្រជាពលរដ្ឋប្រមាណ ១៤,០០០ នាក់ ត្រូវសួរចំលើយ ធ្វើទារុណកម្ម និងសំលាប់[5]។

បញ្ហាទីពីរដែលត្រូវតែដោះស្រាយដែរ គឺអំណះអំណាងរបស់ **ឌុច** ដែលថា គាត់មិនត្រូវឃុំខ្លួនខណៈពេលដែលជនសង្ស័យដទៃទៀតរស់នៅដោយសេរីនោះទេ។ ជំហរបែបនេះត្រូវបានបដិសេធចោល នៅខណៈពេលដែលមានការចាប់ខ្លួន និងចោទប្រកាន់ថ្មីៗ ទៅលើ **នួន ជា** ដែលគេស្គាល់ថាជាបងធំទី២ ដោយអង្គជំនុំជម្រះវិសាមញ្ញ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយមិនគិតពីចាប់ខ្លួននេះ អំណះអំណាងរបស់ **ឌុច** មានទំងន់តិចតួច ពីព្រោះករណីនៃជនសង្ស័យផ្សេងទៀតមិនមែនទទួលខុសត្រូវជំនួសគាត់ឡើយ ហើយដោយនៅចន្លោះពេលនេះ សូមទុកឱ្យតុលាការមានពេលវេលាក្នុងការរៀបចំទៅលើករណីនីមួយៗទៅតាមពេលវេលារបស់ករណីនីមួយៗនោះ។

### ***អនុសាសន៍***

ថ្វីត្បិតតែគណៈកម្មាធិការប្រព្រឹត្តិកម្ម មិនគាំទ្រការសុំដោះលែងឱ្យនៅក្រៅឃុំដល់ **ឌុច** គណៈកម្មាធិការប្រព្រឹត្តិកម្មគាំទ្រសិទ្ធិទទួលបានការកាត់ក្ដីក្នុងរយៈពេលឿនសមរម្យនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ គណៈកម្មាធិការប្រព្រឹត្តិកម្មក៏សូមជំរុញឱ្យអង្គជំនុំជម្រះវិសាមញ្ញពិចារណានូវចំណុចដូចខាងក្រោមៈ

### <u>នៅពេលសវនាការ</u>

គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមតុលាការកុំគិតពិចារណាទៅលើការឃុំខ្លួនខុសច្បាប់កាលពីនៅតុលាការយោធាក្រុងភ្នំពេញ នៅពេលដែលកំណត់អំពីសាលក្រមលើករណី **ឌុច**។ គណៈកម្មាធិការប្រព្រឹត្តិកម្មជឿជាក់ថា ប្រសិនបើធ្វើដូចនេះអាចប៉ះពាល់ឯករាជ្យភាពនៅក្នុងពេលកាត់ក្ដីដោយការវិនិច្ឆ័យទុកជាមុនទៅលើរឿងក្ដីនេះ។ ប្រសិនបើ **ឌុច** មិនត្រូវបានតុលាការរកឃើញថាមានពិរុទ្ធភាពនៅពេលសវនាការ គណៈកម្មាធិការប្រព្រឹត្តិកម្ម សុំជំរុញអង្គជំនុំជម្រះវិសាមញ្ញឱ្យប្រើប្រាស់ការឃុំខ្លួនលើសនីតិវិធីនៅតុលាការយោធា ដើម្បីប្រាប់ដល់រាជរដ្ឋាភិបាលកម្ពុជាចេញសំណងជំងឺចិត្តដល់គាត់។

---

[4] បុព្វកថានៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ

[5] ប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យ (១៩៧៥-១៩៧៩). មជ្ឈមណ្ឌលឯកសារកម្ពុជា. ២០០៧

## ការដាក់ទោស

ប្រសិនបើ **ឌុច** ត្រូវបានតុលាការរកឃើញថាមានពិរុទ្ធភាពនៅពេលមានសវនាការ ការឃុំខ្លួនពីមុនរបស់គាត់ដោយតុលាការយោធាក្រុងភ្នំពេញអាចត្រូវតុលាការយកមកធ្វើជាស្ពានសំរាលទោសសំរាប់គាត់ ។ គណៈកម្មាធិការប្រព្រឹត្តិកម្ម សូមលើកទឹកចិត្តដល់តុលាការកុំឱ្យគិតពិចារណាអំពីការឃុំខ្លួនពីមុននៅក្នុងការកំណត់នូវទោសសមស្របមួយ ប៉ុន្តែក៏រិតទោស ដែលបានកំណត់នោះ ត្រូវតែយកមកពិចារណាផងដែរសំរាប់ការអនុវត្តទោសជាក់ស្តែងទៅលើ **ឌុច** ។

## សន្និដ្ឋាន

វាសំខាន់ណាស់ដែលថា សកម្មភាពរបស់តុលាការយោធាក្រុងភ្នំពេញ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនត្រូវលាយឡំគ្នា ឬភ័ន្តច្រឡំ ។ គណៈកម្មាធិការប្រព្រឹត្តិកម្មជឿជាក់ថា វាជាការសំខាន់ក្នុងការថ្កោលទោសចំពោះសកម្មភាពរបស់តុលាការយោធា និងពេលវេលាឃុំខ្លួន **ឌុច** ដ៏យូរនៅក្រោមអំណាចរបស់តុលាការនេះ ។ ទោះយ៉ាងណា យើងមិនជឿជាក់ថា **ឌុច** នឹងត្រូវតែអង្គជំនុំជម្រះវិសាមញ្ញដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ដោយសារមកពីករណីឃុំខ្លួនពីពេលមុននោះឡើយ ។

គណៈកម្មាធិការប្រព្រឹត្តិកម្មយល់ឃើញថា ការអនុវត្តច្បាប់របស់សហចៅក្រមស៊ើបអង្កេតជាការត្រឹមត្រូវ ក្នុងការសំរេចឃុំខ្លួន **ឌុច** ។ យើងសូមជំរុញឱ្យចៅក្រមឆាប់បើកសវនាការជំនុំជម្រះតាមដែលអាចធ្វើទៅបាន ដើម្បីបន្តធានាថាស្តង់ដារអន្តរជាតិត្រូវបានលើកស្ទួយ ។